# ប្រកាសលេខ ១៤៤

# ស្តីពីបដិបញ្ញត្តិ

# ចំពោះការហាម

# ឃាត់មិនឲ្យប្រើក្មេង

# ធ្វើការពេលយប់

www.ekasar.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ : ១៤៤ សកបយ.

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស

## ស្តីពី

## បដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើ ក្មេងធ្វើការពេលយប់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

ប្រការ១.- ក្មេងដែលមានអាយុពី១៦ឆ្នាំទៅក្រោម១៨ឆ្នាំ អាចប្រើអោយធ្វើការទៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រធ្វើកែវ រោងចក្រធ្វើក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរគគ្រប់ទាំងយប់ទាំងថ្ងៃ ។ ការប្រើក្មេងអោយធ្វើការពេលយប់នៅក្នុងរោងចក្រទាំងនេះមានគោលបំណងតែមួយគត់ គឺដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្មេងតែប៉ុណ្ណោះ ។

ប្រការ២.- ក្នុងគ្រប់ករណីទាំងអស់ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេង មិនអាចលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ហើយ

www.ekasar.com



ការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោចណាស់ ១៣ ម៉ោងជាប់គ្នា។

ប្រការ៣.- និយោជកដែលចង់ប្រើក្មេងពេលយប់ ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេចតាមករណីក្មេងនិមួយៗ ដោយផ្អែកតាមមូលហេតុ នៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេង ដែលចេញដោយគ្រូពេទ្យការងារផង។

ប្រការ៤.- នៅក្នុងគ្រឹះស្ថាន សហគ្រាសទាំងអស់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ និយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អោយធ្វើការនៅពេលយប់បាន ដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្រ បរិក្ខា ឬសម្ភារៈដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើ ត្រូវជូនដំណឹងអោយអធិការការងារបានដឹងជាមុនអំពីមូលហេតុ នៃការធ្វើបដិប្បញ្ញត្តិនេះ។

ប្រការ៥.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៨ សកអ.ប្រក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៦.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៕

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋាន កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហជីពកម្មករ
  "ដើម្បីជ្រាប"
- គ្រប់អង្គភាពពាក់ព័ន្ធ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ